# បទអប់រំខ្លី

## ស្តីអំពី: ដឹកនាំមនុស្សត្រូវដឹកនាំដោយធម៌

បើចង់អោយកូនខ្មែរទៅថ្ងៃអនាគតបានល្អ កូនខ្មែរបច្ចុប្បន្ននេះត្រូវរៀនធ្វើល្អផងដែរ ទឹកដីខ្មែរជាទឹកដីមួយដែលមានមនុស្សរស់នៅអភ័ព្វជាងគេនៅលើលោក ព្រោះប្រទេសនេះត្រូវបានភ្លើងសង្គ្រាមឆេះស្ទើរគ្រប់សម័យកាល ហើយថែមទាំងការដឹកនាំទាំងនោះ មិនប្រកបដោយធម៌ទៀតផង ព្រោះបើតាមការសង្កេតរបស់ខ្ញុំ មានអ្នកដឹកនាំខ្លះឆ្កួតនឹងអំណាច លង់ចាញ់កលបរទេស ចូលចិត្តធ្វើសង្គ្រាម ឈ្លោះគ្នាឯងចូលចិត្តបំផ្លាញកាប់សម្លាប់មនុស្សល្អ មានមនុស្សល្អក៏មិនអាចរស់នៅបានត្រូវរត់ចេញពីប្រទេសរបស់ខ្លួន ដូច្នោះហើយ ទើបធ្វើអោយសង្គមខ្មែរអន់ថយគ្រប់យ៉ាងព្រោះមានមនុស្សល្ងង់រស់នៅច្រើន ។ សេចក្តីល្អល្វតលាស់បានជាមួយមនុស្សល្អតែបើសង្គមនោះមនុស្សល្អមិនអាចនៅបានទេ ក៏ព្រោះត្រូវគ្រប់សង្កត់ដោយពួកជនពាលញាំញីដូច្នោះ មនុស្ស

ល្អរស់នៅលំបាកព្រោះសង្គមនោះមានជនពាលច្រើន ។ អ្នកប្រាជ្ញបណ្ឌិត អ្នកមានទ្រព្យប្រកបដោយធម៌រកស៊ីដោយបញ្ញាកើតបានលំបាកណាស់នៅក្នុងសង្គមខ្មែរ ព្រោះរបបដឹកនាំច្របូកច្របល់មានភាពអយុត្តិធម៌សម្រាប់អ្នកតូចតាច តែមនុស្សអាក្រក់លួងលោភលន់ ច្រើនមានអំណាចគាបសង្កត់អ្នកទន់ខ្សោយគ្មានផ្លូវសូ ។ បើប្រទេសខ្មែរមានមនុស្សល្អចេះដឹងគ្រប់បែបយ៉ាង បានត្រូវប្រើពេលបណ្តុះបណ្តាលកូនខ្មែរ ១០០ឆ្នាំទៀតជាប់តៗគ្នាកុំឲ្យមានសង្គ្រាមកើតឡើង ទើបសង្គមខ្មែរហ្នឹងសម្បូរទាំងអ្នកចេះដឹង អ្នកក្លាហាន បណ្ឌិត អ្នកប្រាជ្ញ អ្នកវិទ្យាសាស្ត្រ កើតច្រើន។ ពេលនោះហើយវត្ថុកសាងនិងគ្រឿងទិកណូឡូជី (Technology) ក៏កើតឡើងតាមផងដែរ តែមនុស្សសម័យនេះត្រូវព្យាយមបង្រៀនចំណេះដឹងល្អៗដល់គ្នា ឬទៅរៀនពីសង្គមដែលគេរីកចម្រើនរុងរឿងទើបមនុស្សខ្មែរទៅអនាគតល្អរុងរឿងបាន។

នយោបាយព្រះពុទ្ធផុតទុក្ខរួចភ័យ មិនមានអាវុធនយោបាយដែលជួយមនុស្សមានចិត្តបរិសុទ្ធនោះ គឺ ព្រះពុទ្ធព្រះអង្គ ជាអ្នកនយោបាយមានបញ្ញាប្រសើរជាងអ្នកនយោ-បាយទាំងឡាយដែលមាននៅក្នុងលោកនេះ លោកមិនត្រូវការអ្វីទេ ឃើញអ្នកនយោបាយជាច្រើនអួតខ្លួនឯងថា ជួយ

មនុស្សអោយរួចចាកទុក្ខ ស្រុកមានសន្តិភាព ខ្លួនមានបញ្ញាចេះដឹងខ្លាំង តែបើមើលទៅពោរពេញដោយសេចក្តីចង់បានភាពជាអ្នកធំណាស់ មានទិដ្ឋិមានះច្រើន ។ ដោយប្រើវិធីនិយាយចាក់ដោតគេ ខ្លះបោកប្រាស់ ខ្លះនិយាយកុហក ខ្លះមូលបង្កាច់គេ ខ្លះប្រើល្បិចកលដើម្បីយកឈ្នះគេ ខ្លះប្លន់ ខ្លះលួច ខ្លះធ្វើសង្គ្រាមដាក់គេ ខ្លះសម្លាប់គេ ខ្លះដើម្បីអំណាចជាធំហ្នឹងឯង។ ដូច្នេះ អ្នកជួយមនុស្សអោយរួចទុក្ខពិតប្រាកដនោះ គឺព្រះពុទ្ធដោយមិនប្រើវិធីអាក្រក់បៀតបៀនជីវិតនណាឡើយ។

ព្រះពុទ្ធទ្រង់បង្រៀនមនុស្សឱ្យយល់ដឹងធម៌ ដើម្បីចេញចាកទុក្ខដោយខ្លួនឯង យ៉ាងណាអ្នកដឹកនាំល្អគប្បីបង្រៀនរាស្ត្រឱ្យចេះដឹងដោះស្រាយបញ្ហា ដោយខ្លួនឯងទើបសង្គមនោះមានភាពសុខស្ងប់ សង្គមជាតិមួយល្អបានព្រោះសង្គមជាតិនោះ ប្រជាជនមានការចេះដឹង សង្គមមួយមានការរីកចម្រើនត្រូវមានកត្តា៣យ៉ាងគឺ៖

១. ត្រូវមាននយោបាយល្អគ្រប់គ្រងប្រទេស

២. ត្រូវមានអ្នកដឹកនាំល្អប្រកបដោយបញ្ញា

៣. ត្រូវមានពលរដ្ឋល្អជាអ្នកចេះដឹងច្រើន៕

ថ្ងៃពុធ ៨រោច ខែពិសាខ ឆ្នាំមមីឆស័ក ព.ស.២៥៥៨
ត្រូវនឹងថ្ងៃទី២១ ឧសភា ឆ្នាំ២០១៤

ដោយ ព្រះភិក្ខុ ធម្មមុនី **ជា ពុទ្ធី**
ផ្នែកខ្លះត្រូវបានកែសម្រួលដោយ
ព្រះមហា ធម្មាលង្ការោ **ចាន់ សុជន**